ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ:១០៨៣
ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៥
សំណុំរឿងជំនុំជម្រះលេខ ២៦៣
ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦
សាលក្រមលេខ ២៨ (៣)
ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈនៅសាលសវនាការលេខ ០១ នៃសាលាដំបូងខេត្តសៀមរាប នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង ០២ និង៣០នាទីរសៀល ដោយមានសមាសភាពជំនុំជម្រះដូចតទៅ ៖

### ចៅក្រមជំនុំជម្រះ

លោកស្រី [redacted] ឋានៈជា ចៅក្រម

### តំណាងអយ្យការ

លោក [redacted] ឋានៈជា ព្រះរាជអាជ្ញារង

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ឋានៈជាក្រឡាបញ្ជី

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ១០៨៣ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៥ ដែលមានជនជាប់ចោទ ៖

(១)- ឈ្មោ[redacted]តុង ភេទប្រុស អាយុ២២ឆ្នាំ សញ្ជាតិខ្មែរ កើតនៅភូមិកូនគ្រៀល ឃុំកូនគ្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ ទីលំនៅបច្ចុប្បន្ននៅភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ[redacted]ស្រី (រ) ម្តាយឈ្មោះ [redacted] ស៊ីណា (រ) នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន។(ក្នុងឃុំ)

ឃុំខ្លួនជាបណ្តោះអាសន្នតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៩៦១ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៥ ។

ជាប់ចោទពីបទ "ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned by CamScanner

(២)- ឈ្មោះ [redacted] សេងនៀន ភេទប្រុស អាយុ៣២ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កំរិតវប្បធម៌គ្មាន កើតនៅភូមិកួនត្រៀល ឃុំកួនត្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ ទីលំនៅបច្ចុប្បន្ននៅភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted](រ) ម្ដាយឈ្មោ[redacted](រ) នៅលីវ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការគ្មាន ។ (ក្រៅឃុំ)

ឃុំខ្លួនជាបណ្ដោះអាសន្នតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៩៦២ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៥ ។

ដីកាបង្គាប់ឲ្យដោះលែងលេខ: ១០៣ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ ។

(៣)- ឈ្មោះ[redacted]ឡោះ ភេទប្រុស អាយុ៣២ឆ្នាំ សញ្ជាតិខ្មែរ មុខរបរធ្វើស្រែ កំរិតវប្បធម៌គ្មាន កើតនៅភូមិចារ ឃុំស្វាយស ស្រុកវ៉ារិន ខេត្តឧត្តរមានជ័យ ទីលំនៅបច្ចុប្បន្ននៅភូមិអូរ ឃុំស្វាយស ស្រុកវ៉ារិន ខេត្តសៀមរាប ឪពុកឈ្មោះ [redacted](រ) ម្ដាយឈ្មោះ [redacted](រ) ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការគ្មាន ។ (ក្រៅឃុំ)

ឃុំខ្លួនជាបណ្ដោះអាសន្នតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៩៦៣ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៥ ។

ដីកាបង្គាប់ឲ្យដោះលែងលេខ: ៥១៥៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ។

ជាប់ចោទពីបទ "ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិជ្រោយនាងនួន ឃុំជ្រោយនាង ស្រុកស្រីស្នំ ខេត្តសៀមរាប កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ៤២ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

-បានឃើញ ដីកាដំណោះស្រាយលេខ ៩៣៤ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាប ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោង០០និង៣០នាទី កម្លាំងសមត្ថកិច្ចការិយាល័យរាជរោទធបាតុប្រឆាំងបទល្មើសគ្រឿងញៀន បានចុះប្រតិបត្តិការបង្ក្រាបបទល្មើសជួញដូរគ្រឿងញៀនខុសច្បាប់ដោយខ្លួនឈ្មោះ [redacted] តុង រកឃើញគ្រឿងញៀនពណ៌សថ្លាចំនួន០៩កញ្ចប់តូច និងជញ្ជីងថ្លឹងគ្រឿងញៀនចំនួន០១គ្រឿង និងថង់ពណ៌សសម្រាប់ច្រកសារធាតុញៀនមួយចំនួន ។ បន្ទាប់ពីឃាត់ខ្លួនឈ្មោះ[redacted]



Scanned by CamScanner

តុង រួចមកសមត្ថកិច្ចកងរាជអាវុធហត្ថបានឲ្យឈ្មោះ [redacted] តុង ចាំទទួលទូរស័ព្ទពីអ្នកតេមកទិញថ្នាំញៀន រហូតឈានដល់ឃាត់ខ្លួនបានចំនួន០៤នាក់រួមមានឈ្មោះ [redacted] សេងលឿន , ឈ្មោះ[redacted] ឡាះ , ឈ្មោះ [redacted] ភីរុណ និងឈ្មោះ [redacted] លីថេង ។ ក្រោយពីបានសាកសួរលើឈ្មោះ [redacted]សេងលឿន បានឆ្លើយថាខ្លួនបានរកប្រាក់ជាមួយមិត្តភក្តិពី០៥ ទៅ ១០ដុល្លា ហើយបានទូរស័ព្ទទិញពីឈ្មោះ តុង ក្នុងតម្លៃ៦០ (ហុកសិប) ដុល្លារ យកមកនាំគ្នាជក់ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ចំណែកឈ្មោ[redacted]ត ឡាះ បានឆ្លើយថាមុនពេលឃាត់ខ្លួនគឺឈ្មោះ រ៉ា បានបបួលខ្លួនជក់ថ្នាំញៀនរួចទៅច្រៀងខារ៉ាអូខេ និងបន្ទាប់មកឈ្មោះ រ៉ា បានឲ្យខ្លួនទៅទិញថ្នាំពីឈ្មោះ តុង ដើម្បីជក់បន្តក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន ។

## នាពេលសវនាការ

-ក្រោយពីបានស្តាប់ចម្លើយ / អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងត្រឹមត្រូវហើយ

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ១០៨៣ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៥ មកជំនុំជម្រះលើជនជាប់ចោទឈ្មោះ [redacted]តុង ពីបទ "ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ឈ្មោះ [redacted]សេងលឿន និងឈ្មោះ[redacted]ឡាះ ពីបទ "ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិជ្រោយនាងនួន ឃុំជ្រោយនាង ស្រុកស្រីស្នំ ខេត្តសៀមរាប កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៥២ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

- តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] តុង បានឆ្លើយ៖ កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែលប្រាំបួនយប់ មានមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះ បានទូរស័ព្ទមកខ្លួនដើម្បីទិញថ្នាំញៀនចំនួនមួយកញ្ចប់ក្នុងតម្លៃ



Scanned by CamScanner

ម៉្ភៃដុល្លារ ហើយបានណាត់គ្នានៅមុំស្តុបឡាបេ ។ ពេលខ្លួនជិះម៉ូតូតែម្នាក់ឯងយកថ្នាំទៅឲ្យអ្នកដែលតេទូរស័ព្ទមកទិញដល់កន្លែងណាត់ជួបក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនភ្លាមៗតែម្តង ។ ពេលសមត្ថកិច្ចឃាត់ខ្លួនបានឆែកហូតថ្នាំញៀនចំនួនប្រាំបួនកញ្ចប់តូច តែថ្នាំចំនួនប្រាំបួនកញ្ចប់នោះជារបស់ឈ្មោះ ប៊ុល ភេទប្រុស អាយុ២៥ឆ្នាំ ដោយឈ្មោះនេះបានឲ្យឈ្មោះ[redacted]ចាន់វិច្ឆិកា ហៅ យុទ្ធ ភេទប្រុស អាយុ២១ឆ្នាំ ជាអ្នករក្សាទុកនិងបានឲ្យខ្លួនយកទៅលក់បន្ត ។ ម៉ូតូដែលខ្លួនជិះជារបស់ឈ្មោះ [redacted] ចាន់វិច្ឆិកា ។ ចំណែកមនុស្សបួននាក់ទៀតដែលបានចាប់បន្តបន្ទាប់នោះ គឺដោយសារឈ្មោ[redacted] ចាន់វិច្ឆិកា បានទុកទូរស័ព្ទនៅខ្លួន ហើយពួកគេបានតេមកទិញជាហូរហែរ ។ កន្លងមកខ្លួនធ្លាប់តែប្រើប្រាស់តែប៉ុណ្ណោះ ដោយមិនធ្លាប់លក់ដូរទេ ទើបតែយកទៅលក់ឲ្យគេម្តងនេះក៏មានបញ្ហាតែម្តង ។ ជនជាប់ចោទសារភាពថាខ្លួនពិតជាខុសមែន ហើយសុំឲ្យតុលាការមេត្តាបន្ធូបន្ថយទោសដល់ខ្លួន ព្រោះខ្លួនដឹងកំហុសហើយ ហើយសន្យាឈប់ប្រព្រឹត្តខុសច្បាប់តទៅទៀត ។

- តាមអំណានចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ[redacted] សេងនឿន បានឆ្លើយថា៖ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោង១២យប់ មិត្តភក្តិឈ្មោះ ពៅ ភេទប្រុស អាយុ៣០ឆ្នាំ សព្វថ្ងៃនៅភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ស្គាល់គ្នាបានរយៈពេលមួយឆ្នាំហើយ ។ ឈ្មោះ ពៅ បានឲ្យខ្លួនទៅរកទិញថ្នាំញៀនយកមកប្រើប្រាស់ជាមួយគ្នា ភ្លាមនោះខ្លួនបានតេទូរស័ព្ទទៅរកទិញពីឈ្មោះ [redacted] តុង ហើយគេប្រាប់ថាមានថ្នាំលក់ និងបានណាត់គ្នាទៅយកនៅក្រុមមាស ។ ពេលទៅដល់មិនទាន់ទាំងបានទិញផងក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ កន្លងមកខ្លួនពុំដែលបានលក់ដូរគ្រឿងញៀនទេ តែធ្លាប់ជក់បានដប់ដងដោយថ្នាំញៀននោះតែងតែទិញពីឈ្មោះ[redacted] តុង ដោយទិញម្តងៗចំនួន១០ដុល្លារ ដោយទិញយកទៅជក់តែម្នាក់ឯងនៅនឹងផ្ទះ ។

- តាមអំណានចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ[redacted] ឡោះ បានឆ្លើយថា ៖ កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោង៩ល្ងាច ខ្លួនបានទូរស័ព្ទទៅឈ្មោះ[redacted] តុង ទិញថ្នាំញៀនចំនួន១២ម៉ឺនរៀល។ ពេលនោះបានណាត់គ្នានៅមុខវិទ្យាល័យ១០មករា តែពេលទៅដល់ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ កន្លងមកខ្លួនមិនដែលលក់ដូរគ្រឿងញៀនទេ តែធ្លាប់ជក់បានម្តងនៅក្រវ៉ាត់ក្រុងជាមួយឈ្មោះ វ៉ា ដែលបានស្គាល់គ្នានៅថៃ ។ នៅថ្ងៃកើតហេតុបានជួបគ្នាម្តងទៀតនៅមុំផ្សារញ៉ើ

ស្រាប់តែឈ្មោះ វ៉ា បានឲ្យប្រាក់ខ្លួនទៅទិញថ្នាំញៀនដើម្បីនាំគ្នាជក់ទៀតក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

-តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំតម្កល់ការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] តុង ពីបទ "ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" តាមមាត្រា៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង ឈ្មោះ [redacted] សេងលឿន និងឈ្មោះ [redacted] ឡោះ ពីបទ "ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" តាមមាត្រា ៤២ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ហើយប្តឹងសុំឲ្យតុលាការសម្រេចផ្តន្ទាទោសតាមច្បាប់ ។ ឃើញថាការប្តឹងសុំរបស់តំណាងអយ្យការមានលក្ខណៈត្រឹមត្រូវ ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] តុង បានលើកឡើងថា ៖ កូនក្តីរបស់ខ្លួនបានសារភាពកំហុសរបស់ខ្លួនអស់ហើយ ហើយជនជាប់ចោទបាននឹងពីកំហុសរបស់ខ្លួន ដោយបានសន្យាថានឹងឈប់ប្រព្រឹត្តអំពើផ្ទុយច្បាប់រដ្ឋទៀតហើយ។ កូនក្តីរបស់ខ្លួន មានកំរិតវប្បធម៌ខ្សោយងាយរងគ្រោះដោយសារការអូសទាញពីមិត្តភក្តិដែលជាហេតុនាំឲ្យមានកំហុសដូចនៅពេលនេះ ។ ដោយកូនក្តីខ្លួនបានសារភាព និងមានឆន្ទៈក្នុងការកែប្រែខ្លួនជាមនុស្សល្អវិញ ក្នុងនាមជាមេធាវីស្នើសុំឲ្យតុលាការមេត្តាបន្ធូបន្ថយទោសដល់កូនក្តីខ្លួន ដោយសុំអនុវត្តទោសមួយចំនួន ហើយព្យួរផ្នែកខ្លះនៃទោស ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សេងនឿង និងឈ្មោះ [redacted] ឡោះ បានលើកឡើងថា ៖ កូនក្តីរបស់ខ្លួនក្រោយពីបាននៅក្រៅឃុំបានកែប្រែខ្លួនហើយ ហើយដោយរវល់នឹងការងារទើបមិនបានចូលរួមសវនការ ។ កូនក្តីរបស់ខ្លួនទាំងពីរនាក់គ្រាន់តែទិញយកទៅប្រើប្រាស់តែប៉ុណ្ណោះ ដោយមិនបានបំណងយកទៅចែកចាយលក់បន្តនោះទេ ។ ហេតុនេះក្នុងនាមជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទស្នើសុំឲ្យតុលាការមេត្តាបន្ធូបន្ថយទោសដល់កូនក្តីខ្លួន និងសុំអនុវត្តទោសព្យួរ ។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] តុង និងភស្តុតាង ឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើ "ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិតាគុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៥ ដូចការចោទប្រកាន់ពិតប្រាកដមែន ។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] សេងលឿន និងឈ្មោះ [redacted] ឡោះ ក្រោយពីបានស្តាប់អំណាន



Scanned by CamScanner

ចម្លើយសារភាព និងភស្តុតាងឃើញថា ជនជាប់ចោទទាំងពីរនាក់ពិតជាបានប្រព្រឹត្ត អំពើ "ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិជ្រោយនាងនួន ឃុំជ្រោយនាង ស្រុកស្រីស្នំ ខេត្តសៀមរាប កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ប្រាកដមែន ។

-អំពើរបស់ជនជាប់ចោទឈ្មោ[redacted]តុង បានឆ្លើយតបបំពេញទៅនឹងធាតុផ្សំនៃបទល្មើស "ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ហើយអំពើរបស់ជនជាប់ចោទឈ្មោះ[redacted]សេងលឿន និងឈ្មោះ[redacted]ឡាះ បានបំពេញធាតុផ្សំនៃបទល្មើស "ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤២ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-ជនជាប់ចោទសុទ្ធតែជានីតិជនមានស្មារតីគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យពីលទ្ធផលនៃអំពើរបស់ខ្លួនតាមផ្លូវច្បាប់ ហើយមានបុគ្គលិកលក្ខណៈពេញលេញក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ។

- ជនជាប់ចោទទាំងអស់ក្រោយពីបានប្រព្រឹត្តនូវអំពើដែលបានចោទប្រកាន់បានសារភាពនូវកំហុសរបស់ខ្លួនចំពោះមុខតុលាការ ហើយបានបង្ហាញពីឆន្ទៈក្នុងការប្រត្តិបត្តិខ្លួនក្នុងការសមាហរណកម្មចូលរួមរស់ក្នុងសង្គមជាពលរដ្ឋល្អវិញ ។ ផ្អែកតាមការដឹងកំហុសនេះ តុលាការនឹងលើមកពិចារណាតាមច្បាប់សមាមាត្រទៅនឹងកំហុសដែលជនជាប់ចោទបានប្រព្រឹត្តកន្លងមក ។

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ និងមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted]តុង ពីបទ "ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ឈ្មោះ[redacted]សេងលឿន និងឈ្មោះ[redacted]ឡាះ ពីបទ "ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិជ្រោយនាងនួន ឃុំជ្រោយនាង ស្រុកស្រីស្នំ ខេត្តសៀមរាប កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤២ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned by CamScanner

## ហេតុដូច្នេះសម្រេច

I-ផ្តន្ទាទោស

ក-ឈ្មោះ [redacted]ង ភេទប្រុស អាយុ២២ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បី) ឆ្នាំ ដោយអនុវត្តទោសពន្ធនាគារកំណត់រយៈពេល ១៨ (ដប់ប្រាំបី) ខែ ពីបទ "ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ-ឈ្មោះ [redacted] សេងនឿន ភេទប្រុស អាយុ៣២ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរ)ឆ្នាំ ។

គ-ឈ្មោ[redacted]ឡោះ ភេទប្រុស អាយុ៣២ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរ)ឆ្នាំ ។

ពីបទ "ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិជ្រោយនាងនួន ឃុំជ្រោយនាងនួន ស្រុកស្រីស្នំ ខេត្តសៀមរាប កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤២ និង៤៥នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

II-វត្ថុតាងរួមមាន ៖

ទូរស័ព្ទម៉ាកណូគាម៉ូឌែល ១០៣៥ ពណ៌សលាយខ្មៅចំនួន០១គ្រឿង ,ម៉ាកណូគាម៉ូឌែល១០៥ ពណ៌ទឹកសមុទ្រចំនួនមួយគ្រឿង , ម៉ាកណូគាម៉ូឌែល ៧២៧០ ពណ៌ខ្មៅចំនួនមួយគ្រឿង , ម៉ាកមិត្តហ្វូនពណ៌សលាយលឿងមួយគ្រឿង , ម៉ាកមិត្តហ្វូនពណ៌ខ្មៅលាយត្រួយចេកមួយគ្រឿង, ម៉ាកខេមហ្វូនពណ៌លឿងលាយខ្មៅមួយគ្រឿង ម៉ាកសាមសុង ពណ៌សលាយខ្មៅ (បែកកញ្ចក់) ចំនួនមួយគ្រឿង ត្រូវសម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ ។ ដោយឡែកជញ្ជីង M3 200G.0.01G ពណ៌ទឹកប្រាក់ចំនួនមួយគ្រឿង , ដែកកេះចំនួនពីរពណ៌ខៀវមួយ និងពណ៌ស្វាយចំនួនមួយ , បំពង់បឺតចំនួនបីកំណាត់តម្របសំបកដបចំនួនមួយ , កូនថង់ផ្លាស្ទីចមួយចំនួន និងម៉ៅគ្រែមពណ៌សថ្លាជាវត្ថុតាងនៃបទល្មើសត្រូវសម្រេចរឹបអូសបំផ្លាញចោល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទ



Scanned by CamScanner

ឈ្មោះ [redacted] គុង កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សេងនឿន និងឈ្មោះ វ៉ាត ឡោះ បើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ៕

ក្រឡាបញ្ជីសវនាការ
ហត្ថលេខានិងត្រា
[redacted]

ចៅក្រមជំនុំជម្រះ
ហត្ថលេខានិងត្រា
[redacted]

បានឃើញ
សៀមរាប, ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦
ចៅក្រមជំនុំជម្រះ
[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
សៀមរាប, ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦
ក្រឡាបញ្ជី
[redacted]



Scanned by CamScanner